# ពត៌មានសំខាន់ស្តីពីហ្វ៊ម៉ាល់ដេហាយដ៍សំរាប់អ្នកតាំងទីលំនៅក្នុងតំបន់របស់ FEMA

### *ហេតុអ្វីបានជាអ្នកទទួលពត៌មាននេះ?*

FEMA ផ្តល់ពត៌មានដើម្បីជួយអ្នកនិងគ្រួសាររបស់អ្នកអោយមានការយល់ដឹងបន្ថែមអំពីហ្វ៊ម៉ាល់ដេហាយដ៍ និងរបៀបដែលវាប៉ះពាល់ដល់ការរស់នៅនិងសុខភាពរបស់គ្រួសារដែលរស់នៅតំបន់ផ្គត់ផ្គង់ដោយ FEMA។ យើងក៏ផ្តល់ដល់អ្នកនូវលេខទូរស័ព្ទដែលអ្នកអាចហៅមកសួរពត៌មានបន្ថែមអំពីហ្វ៊ម៉ាល់ដេហាយដ៍ និងពិភាក្សាអំពីស្ថានភាពភាពគ្រោះថ្នាក់ដល់គេហដ្ឋានរបស់អ្នកជាមួយអ្នកជំនាញរបស់ FEMA ។

### *តើហ្វ៊ម៉ាល់ដេហាយដ៍ជាអ្វី?*

ហ្វ៊ម៉ាល់ដេហាយ៍ជាសារធាតុបង្កខ្យល់កខ្វក់ក្នុងលំនៅដ្ឋានដែលអាចមាននៅស្ទើគ្រប់គេហដ្ឋាននិងអាគារ។ វាជាឧស្ម័នគ្មានពណ៌ដែលសាយភាយក្នុងគេហដ្ឋានតាមរយៈសំភារៈបើប្រាស់ក្នុងផ្ទះមួយចំនួន។ គេក៏រកឃើញហ្វ៊ម៉ាល់ដេហាយដ៍មាននៅនឹងសំភារៈសំណង់ និងផលិតផលសំរាប់ប្រើប្រាស់ក្នុងផ្ទះមួយចំនួនទៀត។

### *តើហ្វ៊ម៉ាល់ដេហាយដ៍អាចប៉ះពាល់ដល់សុខភាពខ្ញុំនិងគ្រួសារខ្ញុំដោយរបៀបណា?*

គេអង្កេតឃើញមានរោគសញ្ញាមួយចំនួនដែលទាក់ទងនឹងហ្វ៊ម៉ាល់ដេហាយដ៍ដូចជាៈ ហៀរទឹកភ្នែក ហៀរសំបោរ មានអារម្មណ៍ក្តៅភ្នែក ក្តៅច្រមុះ និងបំពង់ករ ឈឺក្បាល និងអស់កំលាំងល្ហិតល្ហៃ។ រោគសញ្ញាណទាំងនេះស្រដៀងនឹងរោគសញ្ញាគ្រុនផ្តាសាយ គ្រុនក្តៅ និងរោគសញ្ញាបណ្តាលពីខ្យល់កខ្វក់ផ្សេងៗដែរ។

ហ្វ៊ម៉ាល់ដេហាយដ៍អាចមានឥទ្ធិពលខុសៗគ្នាទៅលើបុគ្គលខុសគ្នា។ បុគ្គលខ្លះអាចគ្មានប្រតិកម្មគួរអោយកត់សំគាល់ណាមួយទៅនឹង ហ្វ៊ម៉ាល់ដេហាយដ៍ រីឯបុគ្គលខ្លះទៀតអាចងាយមានអារម្មណ៍បំផុត។ បុគ្គលដែលមានបញ្ហាអាលាក់ហ្ស៊ីភ្នែក ស្បែក ផ្លូវដង្ហើម រឺមានរោគហឺត ងាយមានអារម្មណ៍ប្រតិកម្មនឹងហ្វ៊ម៉ាល់ដេហាយដ៍។ កូនក្មេងតូចៗ និងមនុស្សចាស់ជរាក៏អាចងាយមានប្រតិកម្ម។

កត្តារួមដែលងាយទទួលប៉ះពាល់នឹងហ្វ៊ម៉ាល់ដេហាយដ៍គឺតាមការដកដង្ហើម។ ការដកដង្ហើមបណ្តាលអោយរមាស់ភ្នែក និងបំពង់ករទោះបីប៉ះពាល់កំរិតទាបក៏ដោយ។ បុគ្គលដែលប៉ះពាល់ហ្វ៊ម៉ាល់ដេហាយដ៍ច្រើនអាចបណ្តាលអោយគ្រោះថ្នាក់ធ្ងន់ធ្ងរដល់សុខភាព គឺវាអាចនឹងបណ្តាលអោយកើតជំងឺមហារីកផ្សេងៗទៀតផង។

ប្រសិនបើរោគសញ្ញាថយចុះនៅពេលអ្នកស្ថិតនៅឆ្ងាយពីលំនៅដ្ឋាន ប៉ុន្តែវារើឡើងវិញធ្ងននៅពេលអ្នកត្រឡប់មកផ្ទះ រោគសញ្ញានោះអាចបណ្តាលមកពីខ្យល់កខ្វក់ក្នុងផ្ទះដែលបណ្តាលមកពីធូរលី ផ្សែងបារី រឺហ្វ៊ម៉ាល់ដេហាយដ៍។

ប្រសិនបើអ្នកធ្លាប់មានរោគសញ្ញាទាំងនេះ រឺមានអារម្មណ៍សង្ស័យថារោគសញ្ញារបស់អ្នកអាចបណ្តាលមកពីហ្វ៊ម៉ាល់ដេហាយដ៍ អ្នកគួរតែទៅជួបគ្រូពេទ្យដើម្បីពិគ្រោះ។

## ពត៌មានបន្ថែម

ប្រសិនបើអ្នកមានសំនួររឺភាពកង្វល់បន្ថែមទាក់ទងនឹងហ្វ៊ម៉ាល់ដេហាយដ៍នៅលំនៅដ្ឋានរបស់អ្នក សូមទំនាក់ទំនងៈ

**១-៨៦៦-៥៦២-២៣៨១**
**(TTY ១-៨០០-៤៦២-៧៥៨៥)**

អ្នកទទួលទូរស័ព្ទរបស់ FEMA នឹងតភ្ជាប់ការហៅរបស់អ្នកទៅអ្នកជំនាញដែលអាចឆ្លើយតបនឹងសំនួរទាក់ទងនឹងៈ

- បញ្ហាទាក់ទងនឹងសុខភាព និងហ្វ៊ម៉ាល់ដេហាយដ៍
- ជំនួយជំរើសផ្សេងៗទាក់ទងនឹងលំនៅដ្ឋានដែល FEMA ផ្តល់ជូន និង
- លំនៅដ្ឋាន FEMA ដែលទើបនឹងទិញថ្មី